# ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៧៤

## យើង

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកដោះស្រាយកិច្ចការព្រំដែន

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រាមួយ** : ត្រូវបានកែសម្រួលមាត្រា១ មាត្រា២ មាត្រា៣ មាត្រា៤ មាត្រា៥ និងមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៦ ដែលមានខ្លឹមសារដូចតទៅ :

**មាត្រា១ថ្មី** : បង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដែលមានសមាសភាពដូចតទៅ :

| | |
|---|---|
| ១-នាយករដ្ឋមន្ត្រី | ប្រធាន |
| ២-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធានអចិន្ត្រៃយ៍ |
| ៣-រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |

៤-សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អនុប្រធាន
៥-សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អនុប្រធាន
៦-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៧-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ សមាជិក
៨-ឯកឧត្តម វ៉ា គឹមហុង ទីប្រឹក្សារាជរដ្ឋាភិបាលទទួលបន្ទុកកិច្ចការព្រំដែន និងជាប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍មានឋានៈស្មើទេសរដ្ឋមន្ត្រី សមាជិក
៩-ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស សមាជិក
១០-អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក

**មាត្រា២ថ្មី** : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានភារកិច្ច :

-រៀបចំ និងកសាងលិខិតបទដ្ឋានមានលក្ខណៈច្បាប់ ស្តីពីការកំណត់ព្រំដែនដីគោក និងព្រំដែនសមុទ្រ ដើម្បីយកទៅតម្កល់នៅទីស្នាក់ការអង្គការសហប្រជាជាតិ ។

-សិក្សា ស្រាវជ្រាវ ឱ្យបានហ្មត់ចត់បំផុត ក្នុងការជ្រើសរើសយកផែនទីសម្រាប់ធ្វើការកំណត់ខ្សែបន្ទាត់ព្រំដែនដីគោក និងព្រំដែនសមុទ្រឱ្យបានច្បាស់លាស់រវាងព្រះរាជាណាចក្រកម្ពុជា ជាមួយប្រទេសជិតខាង ។

-ធ្វើការចរចា សម្របសម្រួល ដោះស្រាយ និងសម្រេចលើបញ្ហាព្រំដែនជាមួយប្រទេសជិតខាង លើរាល់កិច្ចការដែលមានទំនាក់ទំនងលើការងារព្រំដែន ក្រោយពីមានការឯកភាពពីរាជរដ្ឋាភិបាល ។

-លើកគំរោងអភិវឌ្ឍន៍តំបន់ព្រំដែន ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ។

-ប្រធានអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានសិទ្ធិចុះហត្ថលេខាលើសន្ធិសញ្ញាស្តីពីបញ្ហាព្រំដែន ជាមួយប្រទេសជិតខាង ។

-ធ្វើរបាយការណ៍តាមដំណាក់កាលនីមួយៗ អំពីសកម្មភាពរបស់ខ្លួន ជូនក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ។

**មាត្រា៣ថ្មី** : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានយន្តការពីរ ជាសេនាធិការ :

<u>យន្តការទី១</u> : ជាគណៈកម្មាធិការនីតិកម្មនិងបច្ចេកទេសកិច្ចការព្រំដែន ដែលមានភារកិច្ចៈ

-សិក្សា ស្រាវជ្រាវ ដើម្បីរៀបចំឯកសារជាលក្ខណៈច្បាប់ ទាំងព្រំដែនគោក ទាំងព្រំដែនសមុទ្រជាមួយប្រទេសជិតខាង ធ្វើជាមូលដ្ឋានបង្អែកសម្រាប់ពិភាក្សាជាមួយប្រទេសជិតខាង។

-ធ្វើការចរចាជាមួយប្រទេសជិតខាង ក្នុងការកំណត់ជ្រើសរើសយកផែនទីសម្រាប់ធ្វើការវាស់វែងខ្សែបន្ទាត់ព្រំដែន ។

-ចុះធ្វើការវាស់វែង កំណត់ខ្សែបន្ទាត់ព្រំដែន ខណ្ឌព្រំសីមា និងបោះបង្គោលព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយប្រទេសជិតខាង ។

-ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនតាមការកំណត់ ផ្ញើជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

សមាសភាពនៃគណៈកម្មាធិការនេះ កំណត់ដោយអនុក្រឹត្យ ។

<u>យន្តការទី២</u> : ជាគណៈកម្មាធិការត្រួតពិនិត្យ ដោះស្រាយបាតុភាព និងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនជាមួយប្រទេសជិតខាង ដែលមានភារកិច្ច:

-ត្រួតពិនិត្យកិច្ចការការពារខ្សែបន្ទាត់ព្រំដែន នៃព្រះរាជាណាចក្រកម្ពុជា ។

-ធ្វើអន្តរាគមន៍ដោះស្រាយចំពោះបាតុភាព ឬទំនាស់ព្រំដែនជាមួយខេត្តជាប់ព្រំដែន របស់ប្រទេសជិតខាង តាមស្មារតីនៃលទ្ធផលស្តីពីដំណោះស្រាយបញ្ហាព្រំដែន ដែលទទួលបានពីអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

-ចូលរួមជាមួយគណៈកម្មាធិការនីតិកម្ម និងបច្ចេកទេស ក្នុងការចរចាដោះស្រាយបញ្ហាព្រំដែន ជាមួយប្រទេសជិតខាងតាមការចាំបាច់ ។

-លើកគំរោងអភិវឌ្ឍន៍តំបន់ព្រំដែន ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

-ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនតាមការកំណត់ ផ្ញើជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

សមាសភាពនៃគណៈកម្មាធិការនេះ កំណត់ដោយអនុក្រឹត្យ ។

**មាត្រា៤ថ្មី** : យន្តការទាំងពីរនេះ មានលេខាធិការដ្ឋានរួមមួយ នៅទីស្តីការគណៈរដ្ឋមន្ត្រី ហៅថា : លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដែលមាន :

-ឯកឧត្តម **វ៉ា គឹមហុង** ប្រធាន

-ឯកឧត្តម **ហួន សារ៉ាង** អនុប្រធាន

មានឋានៈស្មើអនុរដ្ឋលេខាធិការបន្ថែមលើមុខងារបច្ចុប្បន្ន

-លោកជំទាវ **គុយ ពិសី** លេខាធិការ

មានឋានៈស្មើអគ្គនាយក

-ប្រធាន នាយកដ្ឋានភូមិសាស្ត្រ សមាជិក

-ប្រធាន នាយកដ្ឋានសុរិយោដី សមាជិក

-មន្ត្រីជំនាញមួយចំនួន តាមសេចក្តីត្រូវការជាក់ស្តែង

លេខាធិការដ្ឋាននេះ ជាអ្នកសម្របសម្រួលកិច្ចការរវាងគណៈកម្មាធិការនីតិកម្ម និងបច្ចេកទេសស្តីពីកិច្ចការព្រំដែន និងគណៈកម្មាធិការត្រួតពិនិត្យ ដោះស្រាយបាតុភាព និងអភិវឌ្ឍន៍នៅតាមបណ្តោយខ្សែព្រំដែនជាមួយប្រទេសជិតខាង ហើយជាក្បាលម៉ាស៊ីនរដ្ឋបាល និងជាហិរញ្ញកិច្ចរបស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដោយប្រើប្រាស់មន្ត្រីរបស់ទីស្តីការគណៈរដ្ឋមន្ត្រី មន្ត្រីរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (នាយកដ្ឋានភូមិសាស្ត្រ និងនាយកដ្ឋានសុរិយោដី) និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ សម្រាប់ជំនួយការ ។

លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ត្រូវកសាងផែនការចំណាយរបស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

**មាត្រា៥ថ្មី** : លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានភារកិច្ច :

-សិក្សាស្រាវជ្រាវនិងស្វែងយល់បន្ថែមលើការងារបច្ចេកទេស ដែលពាក់ព័ន្ធនឹងបញ្ហាព្រំដែន ដើម្បីរៀបចំ និងកសាងឱ្យបានលិខិតបទដ្ឋានមានលក្ខណៈច្បាប់សម្រាប់យកទៅដាក់ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

-ចុះពិនិត្យ និងធ្វើការវាស់វែងដល់ទីកន្លែងកើតហេតុ និងបាតុភាពនានាតាមបណ្តោយព្រំដែន រួចរាយការណ៍ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដើម្បីពិនិត្យ និងសម្រេច។

-ចូលរួមក្នុងការចរចាជាមួយប្រទេសជិតខាង ដើម្បីកំណត់ជ្រើសរើសយកផែនទីសម្រាប់ធ្វើជាមូលដ្ឋានក្នុងការដោះស្រាយបញ្ហាបច្ចេកទេសឱ្យបានត្រឹមត្រូវច្បាស់លាស់ ។

-លើកគម្រោងអភិវឌ្ឍន៍តំបន់ព្រំដែន ដាក់ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដើម្បីពិនិត្យ និងសម្រេច ។

-សហការជាមួយអភិបាល ឬអភិបាលរងខេត្ត ក្រុង ដែលនៅជាប់ព្រំដែនជាមួយប្រទេសជិតខាងក្នុងការសិក្សាស្រាវជ្រាវលើទីតាំងបង្គោលសីមាព្រំដែន និងខ្សែបន្ទាត់ព្រំដែនជាក់ស្តែងទៅនឹងបញ្ហាបច្ចេកទេសជំនាញ រួចរាយការណ៍អំពីលទ្ធផលជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

-ធ្វើរបាយការណ៍តាមការកំណត់ អំពីសភាពការណ៍នៃការដោះស្រាយ និងការកំណត់ព្រំដែនជាមួយប្រទេសជិតខាងជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន សម្រាប់រាយការណ៍ជូនរាជរដ្ឋាភិបាល ថ្នាក់ និងជូនក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ។

**មាត្រា៦ថ្មី** : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី សម្របសម្រួលការងារ ។ សមាជិកអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**មាត្រាពីរ** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រាបី** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រាបួន** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត-០៥០៦-២៩១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០៥

លេខ ៦៤៣ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សខាធី តាន់**